Washington State Department of Social & Health Services
Transforming lives

# គោលការណ៍ណែនាំសម្រាប់ការបំពេញ ICAP / កម្រិតនៃឥរិយាបថក្នុងការសម្របខ្លួននៃ SIB-R
## Guidelines for Completing the ICAP / SIB-R Adaptive Behavior Scale

ផ្នែកឥរិយាបថក្នុងការសម្របខ្លួនរបស់ ICAP វាយតម្លៃអំពីជំនាញនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់អ្នកដាក់ពាក្យស្នើសុំ និងការយល់ដឹងរបស់អ្នកដាក់ពាក្យស្នើសុំអំពី*ពេលវេលា*ដែលត្រូវអនុវត្តជំនាញទាំងនេះ។ គោលដៅ គឺដើម្បីទទួលបានចំណាប់អារម្មណ៍ត្រឹមត្រូវសាអំពីសមត្ថភាពរបស់គាត់/នាង។ ពិន្ទុឥរិយាបថក្នុងការសម្របខ្លួនរបស់អ្នកដាក់ពាក្យស្នើសុំណាម្នាក់អាចត្រូវបានដាក់កំហិតមួយចំនួន ប្រសិនបើគាត់/នាងខ្វះខាតសមត្ថភាពផ្នែកខួរក្បាល ឬការយល់ដឹងអំពីពេលវេលាដែលត្រូវអនុវត្តជំនាញណាមួយឲបានសមស្របដោយមិនចាំបាច់មានការស្នើសុំ ឬរំឭកម្តងហើយម្តងទៀតនោះទេ។

ធ្វើ (ឬអាចធ្វើ) កិច្ចការបានយ៉ាងពេញលេញដោយគ្មានជំនួយ ឬការត្រួតពិនិត្យនោះទេ

*ធ្វើកិច្ចការបានយ៉ាងពេញលេញ*មានន័យថាគ្រប់ផ្នែកទាំងអស់នៃកិច្ចការមួយ។ ចំណុចនៃឥរិយាបថក្នុងការសម្របខ្លួនរបស់ ICAP មួយចំនួនមានលើសពីមួយផ្នែក។ ប្រសិនបើមនុស្សម្នាក់ធ្វើកិច្ចការមួយផ្នែកបានល្អណាស់ ប៉ុន្តែធ្វើបានល្អបង្គួរតែប៉ុណ្ណោះចំពោះផ្នែកផ្សេងទៀត ចូរដាក់ចំណាត់ថ្នាក់ចំណុចនោះថាធ្វើបានល្អបង្គួរតែប៉ុណ្ណោះ។

*អាចធ្វើបាន។* នៅក្នុងករណីដែលកម្រ ប្រហែលជាអាចមានចំណុចណាមួយដែលអ្នកដាក់ពាក្យស្នើសុំណាម្នាក់មានភាពស្ទាត់ជំនាញ ឬមានភាពស្ទាត់ជំនាញមួយផ្នែក ប៉ុន្តែគ្មានឱកាសនៅក្នុងការអនុវត្ត។ សកម្មភាពនោះប្រហែលជាមិនអាចស្វែងរកបាន ប្រឆាំងនឹងច្បាប់ ឬវាប្រហែលជា "ការងាររបស់អ្នកណាម្នាក់ផ្សេងទៀត"។ នៅក្នុងករណីនេះ ចូរធ្វើការប៉ាន់ស្មានថាតើបុគ្គលម្នាក់នោះនឹងអាចធ្វើកិច្ចការនោះបានល្អដល់កម្រិតណា នៅពេលនេះដោយគ្មានការបណ្តុះបណ្តាលបន្ថែម គ្មានជំនួយ ឬការត្រួតពិនិត្យនោះទេ ប្រសិនបើមានឱកាស។

*ដោយគ្មានជំនួយ ឬគ្មានការត្រួតពិនិត្យ។* នេះមានន័យថា អ្នកដាក់ពាក្យស្នើសុំធ្វើកិច្ចការណាមួយដោយឯករាជ្យ។ ការប្រាប់ ឬការរំឭកតែមួយលើក ម្តងម្កាលអាចទទួលយកបាន។ ទោះបីជាយ៉ាងណាក៏ដោយ ការស្នើសុំម្តងហើយម្តងទៀត ឬការប្រាប់មួយជំហានម្តងៗ ឬការរំឭក បង្កើតជាជំនួយ ឬការត្រួតពិនិត្យ។ នៅក្នុងតំបន់នីមួយៗនៃតំបន់ទាំងបួននៃឥរិយាបថក្នុងការសម្របខ្លួនរបស់ ICAP ចំណុចនានាត្រូវបានតំរៀបតាមលំដាប់លំដោយនៃការពិបាកជាមធ្យម ពីកម្រិតទារកភាពរហូតដល់កម្រិតមនុស្សពេញវ័យដែលមានភាពចាស់ទុំ។ ចំណុចនីមួយៗត្រូវបានដាក់ពិន្ទុតាមកម្រិតពី 0 រហូតដល់ 3 អាស្រ័យលើសមត្ថភាពរបស់អ្នកដាក់ពាក្យស្នើសុំនៅក្នុងការធ្វើកិច្ចការនោះដោយគ្មានជំនួយ ឬការត្រួតពិនិត្យ។

ធ្វើបានល្អណាស់។ នេះចង្អុលបង្ហាញអំពីភាពឯករាជ្យយ៉ាងពេញលេញចំពោះកិច្ចការណាមួយ។ អ្នកដាក់ពាក្យស្នើសុំមានភាពស្ទាត់ជំនាញចំពោះកិច្ចការនោះ ឬឈប់ធ្វើវាទៀតហើយ ពីព្រោះវាស្រួលពេក (ឧទាហរណ៍ ៖ តាមធម្មតា ទទួលទានអាហារដោយប្រើសមច្រើនជាងស្លាបព្រា, តាមធម្មតា ដើរច្រើនជាងវារ)។ មនុស្សម្នាក់នោះធ្វើកិច្ចការគ្រប់ផ្នែកទាំងអស់ដោយគ្មានជំនួយ ឬគ្មានការត្រួតពិនិត្យនោះទេ។

ជានិច្ច ឬស្ទើរតែជានិច្ច – ដោយគ្មានការស្នើសុំ។ *ជានិច្ច* មានន័យថា នៅពេលណាមួយក៏ដោយ ដែលវាមានភាពសមស្របនៅក្នុងការធ្វើបែបនោះ។ *ដោយគ្មានការស្នើសុំ* មានន័យថា ដោយគ្មានអ្វីផ្សេងលើសពីការរំឭកម្តងម្កាលនោះទេ។ អ្នកស្នើសុំត្រូវតែកាន់កាប់ជាកម្មសិទ្ធិលើជំនាញនោះ *និង*ដឹងអំពីពេលវេលាដែលត្រូវប្រើវា ស្របតាមស្តង់ដារសង្គមធម្មតា។ វាមិនអីនោះទេ ប្រសិនបើមនុស្សម្នាក់នោះស្នើសុំការអនុញ្ញាតមុនពេលចាប់ផ្តើមធ្វើកិច្ចការយ៉ាងសមស្រប។

ធ្វើបានល្អបង្គួរ។ នេះចង្អុលបង្ហាញថា អ្នកដាក់ពាក្យស្នើសុំធ្វើកិច្ចការគ្រប់ផ្នែកទាំងអស់បានល្អគួរសមដោយគ្មានជំនួយ ឬការត្រួតពិនិត្យនោះទេ។

ឬ ¾ នៃពេលវេលា – ប្រហែលជាចាំបាច់ត្រូវតែមានការស្នើសុំ។ នេះអាចត្រូវបានបកស្រាយថា មានន័យថា កិច្ចការនោះធ្វើបានល្អបង្គួរ ដែលវាត្រូវបានធ្វើបានយ៉ាងល្អនៅ ¾ នៃពេលវេលា ឬថាវាត្រូវបានធ្វើដោយគ្មានជំនួយ ឬគ្មានការត្រួតពិនិត្យនៅ ¾ នៃពេលវេលា។ វាមិនអីនោះទេ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំចាំបាច់ត្រូវតែបានស្នើសុំ ឬរំឭកឲចាប់ផ្តើមធ្វើកិច្ចការនោះ។

ធ្វើ ប៉ុន្តែមិនបានល្អនោះទេ។ នេះចង្អុលបង្ហាញថា អ្នកដាក់ពាក្យស្នើសុំ នៅពេលខ្លះ ធ្វើ ឬព្យាយាមធ្វើកិច្ចការគ្រប់ផ្នែកទាំងអស់ដោយគ្មានជំនួយ ឬគ្មានការត្រួតពិនិត្យ ប៉ុន្តែលទ្ធផលគឺមិនល្អនោះទេ។

ឬ ¼ នៃពេលវេលា – ប្រហែលជាចាំបាច់ត្រូវតែមានការស្នើសុំ។ នេះចង្អុលបង្ហាញថា មានន័យថា កិច្ចការត្រូវបានធ្វើ ប៉ុន្តែមិនបានល្អនោះទេ ថាវាត្រូវបានធ្វើបានយ៉ាងល្អនៅ ¼ នៃពេលវេលា ឬថាវាត្រូវបានធ្វើដោយគ្មានជំនួយ ឬគ្មាន ការត្រួតពិនិត្យនៅ ¼ នៃពេលវេលា។ វាមិនអីនោះទេ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំចាំបាច់ត្រូវតែបានស្នើសុំ ឬរំឭកឲចាប់ផ្តើមធ្វើកិច្ចការនោះ។

មិនធ្លាប់ ឬកម្រ។ នេះចង្អុលបង្ហាញថា កិច្ចការនោះពិបាកពេក ដែល អ្នកដាក់ពាក្យស្នើសុំមិនត្រូវបានអនុញ្ញាតឲធ្វើកិច្ចការនោះទេ ពីព្រោះវាគ្មានសុវត្ថិភាព ឬថាមនុស្សម្នាក់នោះមិនធ្លាប់ ឬកម្រធ្វើកិច្ចការនោះគ្រប់ផ្នែកណាស់។

ទោះបីជាត្រូវបានស្នើសុំក៏ដោយ។ មិនធ្លាប់ធ្វើបានល្អនោះទេ ទោះបីជាត្រូវបានស្នើសុំ ឬត្រូវបានប្រាប់ក៏ដោយ។

តើល្អដល់កម្រិតណា គឺ “ល្អ?”

ICAP ត្រូវបានកំណត់បទដ្ឋាននៅលើ 1.764 នៃបុគ្គលដែលមិនពិការ ដែលមានវ័យចាប់ពីទារកដែលមានអាយុតិចជាងបីខែរហូតដល់មនុស្សពេញវ័យដែលមានភាពចាស់ទុំ។ មាតាបិតាបានប្រើកម្រិតនៃការវាយតម្លៃរបស់ ICAP ដូចបានពណ៌នានៅខាងលើដើម្បីវាយតម្លៃលើកូនៗរបស់ពួកគេ (និងមនុស្សពេញវ័យប្រើវាដើម្បីវាយតម្លៃលើខ្លួនឯង) ចំពោះចំណុចនីមួយៗរបស់ ICAP។ ពួកគេយល់ឃើញថា កិច្ចការនេះមាន ភាពសាមញ្ញគួរសម និងទៀងត្រង់។ ពួកគេមិនត្រូវបានផ្តល់ជូន ហើយពួកគេក៏មិនបានស្នើសុំព័ត៌មានបន្ថែមអំពីចំណុចនីមួយៗនោះទេ។

ចំណុចនានានៃឥរិយាបថក្នុងការសម្របខ្លួនរបស់ ICAP គឺស្ថិតនៅតាមលំដាប់លំដោយនៃការអភិវឌ្ឍ។ នៅក្នុងការកំណត់ថាតើចំណុចនីមួយៗត្រូវបានធ្វើបានល្អប៉ុណ្ណោះ មាតាបិតាបានប្រើប្រាស់កុមារដែលមានវ័យប្រហាក់ប្រហែលគ្នាផ្សេងទៀត និងសកម្មភាពប្រចាំថ្ងៃរបស់ពួកគេជាបរិបទនៅក្នុងការវិនិច្ឆ័យអំពីភាពជោគជ័យដែលពាក់ព័ន្ធ។ ឧទាហរណ៍ ៖ ប្រើប្រាស់ចំណុចនៃ *ការកាត់ដោយប្រើកន្ត្រៃតាមបណ្តោយបន្ទាត់ត្រង់ក្រាស់មួយ*។ នេះគឺជាជំនាញមួយ ដែលតាមធម្មតា គឺជាជំនាញរបស់កុមារដែលមានអាយុ 3 ឆ្នាំ។ តើបន្ទាត់ក្រាស់មួយមានកម្រាស់ក្រាស់ដល់កម្រិតណា? តើបន្ទាត់ត្រង់មានភាពត្រង់ដល់កម្រិតណា? ចាត់ទុកខ្លួនអ្នកជាមាតាបិតា ធ្វើការអង្កេតអំពីសកម្មភាពនៅសាលាមត្តេយ្យធម្មតាមួយ។ បន្ទាត់ក្រាស់ប្រហែលជាបន្ទាត់មួយដែលត្រូវបានគូរដោយហ្វឺតវេទមន្តមួយ។ ការកាត់ដ៏ត្រង់មួយអាចជាការកាត់ ដែលស្ថិតនៅក្នុងចម្ងាយប្រាំបីអ៊ីញពីបន្ទាត់នោះ។

ប្រសិនបើអ្នកមានការពិបាកចំពោះពាក្យនានា ដូចជា *សាមញ្ញ* ឬ*ស្អាតបាត* ឬ*សមរម្យ* ចូរសួរខ្លួនអ្នកនូវសំណួរនេះ ៖ តើកម្រិតនៃការអភិវឌ្ឍប្រហាក់ប្រហែលនៃចំណុចនេះចំពោះបុគ្គលដែលមិនពិការ គឺស្ថិតនៅកម្រិតណា? តើស្តង់ដារសម្រាប់ភាពជោគជ័យបែបណាខ្លះ ដែលមាតាបិតា ឬគ្រូបង្រៀនរបស់កុមារដែលស្ថិតនៅក្នុងវ័យនេះ អាចនឹងប្រើប្រាស់?

តើបន្ទប់ដ៏ស្អាតមួយមានភាពស្អាតដល់កម្រិតណា? មាតាបិតារបស់កុមារដែលមានវ័យ 11 – 15 ឆ្នាំ រំពឹងទុកថា កូនៗរបស់ពួកគេនឹងចាប់ផ្តើមមានទំនួលខុសត្រូវនេះ។ តើមាតាបិតារបស់កុមារដែលមានវ័យនេះជាមធ្យម កំពុងតែគិតអំពីអ្វីនៅពេលដែលគាត់/នាងបាននិយាយថា “ធ្វើប៉ុន្តែមិនបានល្អនោះទេ” ឬ “ធ្វើបានល្អណាស់”?

ការពិបាក នៅពេលខ្លះ កើតឡើងនៅពេលធ្វើការវាយតម្លៃអំពីមនុស្សពេញវ័យដែលពិការខួរក្បាល ឬពិការផ្លូវកាយ ពីព្រោះបរិបទនៃឥរិយាបថមួយអាចមានភាពខុសប្លែកពីធម្មតា។ ទោះបីជាយ៉ាងណាក៏ដោយ ស្តង់ដារសម្រាប់ភាពជោគជ័យគួរតែដូចគ្នា ពីព្រោះស្តង់ដារនោះគឺសម្រាប់ក្រុមកំណត់បទដ្ឋាន។

ការបែងចែកភាពខុសគ្នារវាងឥរិយាបថនៃការសម្របខ្លួន ឥរិយាបថនៃការមិនសម្របខ្លួន និងឥរិយាបថនៃការមិនសហការ។

ប្រសិនបើមានភាពខុសគ្នារវាងគុណភាពនៃការអនុវត្តរបស់អ្នកដាក់ពាក្យស្នើសុំណាម្នាក់ (ឧ. តែងតែធ្វើបានល្អជានិច្ច ឬស្ទើរតែជានិច្ច) និងភាព ញឹកញាប់ (ឧ. ¾ នៃពេលវេលា) នោះ ពិន្ទុគួរតែផ្អែកជាចម្បងលើគុណភាពនៃការអនុវត្ត។ ផ្នែកឥរិយាបថក្នុងការសម្របខ្លួនរបស់ ICAP ផ្តោតលើសមត្ថភាព។ អ្នកណាម្នាក់ដែលនឿយហត់ ខឹង ឬច្រឡោត នៅពេលខ្លះ បដិសេធមិនធ្វើកិច្ចការណាមួយនោះទេ នៅតែត្រូវបានវាយតម្លៃថា *ធ្វើបានល្អដោយគ្មានការស្នើសុំ* ប្រសិនបើជំនាញនោះស្ថិតនៅក្នុងសមត្ថភាពរបស់គាត់ ហើយតាមធម្មតា គាត់ធ្វើបានល្អ។ ប្រសិនបើការបដិសេធនៅតែបន្តកើតឡើង ប៉ុន្តែចំពោះតែកិច្ចការនៃការសម្របខ្លួនយ៉ាងជាក់លាក់តែពីរបីប៉ុណ្ណោះ ភាគច្រើន វាអាចកាត់បន្ថយពិន្ទុនៃការវាយតម្លៃអំពីការសម្របខ្លួនរបស់អ្នកដាក់ពាក្យស្នើសុំមួយពិន្ទុចំពោះចំណុចជាក់លាក់ទាំងនេះ។ នៅក្នុងការថែទាំនេះ ការមិនសហការមិនត្រូវបានវាយតម្លៃថាជាបញ្ហានៃឥរិយាបថមួយនោះទេ។

ឥរិយាបថដែលជ្រៀតជ្រែកចំពោះសកម្មភាពប្រចាំថ្ងៃរបស់ អ្នកដាក់ពាក្យស្នើសុំណាម្នាក់ ឬចំពោះសកម្មភាពរបស់អ្នកដែលនៅជុំវិញគាត់/នាង គួរតែត្រូវបានវាយតម្លៃថាជាបញ្ហានៃឥរិយាបថ *មិនមែន*ជាការខ្វះខាតឥរិយាបថក្នុងការសម្របខ្លួននោះទេ។ ការបដិសេធមិនធ្វើកិច្ចការចាំបាច់នានាដែលស្ថិតនៅក្នុងសមត្ថភាពរបស់មនុស្សម្នាក់ ដែលនៅពេលខ្លះត្រូវបានហៅថាបដិលោមភាពនៃឥរិយាបថនៃការមិនសហការ អាចត្រូវបានកត់ត្រានៃក្នុងផ្នែកឥរិយាបថដែលមានបញ្ហារបស់ ICAP ប្រសិនបើការបដិសេធនោះមានភាពទូទៅគ្រប់គ្រាន់នៅក្នុងការបង្កើតជាបញ្ហាមួយដែលកើតឡើងជាបន្តបន្ទាប់នៅក្នុងជំនាញជាច្រើននៃការសម្របខ្លួន។ នៅក្នុងករណីនេះ ការមិនសហការរបស់អ្នកដាក់ពាក្យស្នើសុំណាម្នាក់នឹងមិនកាត់បន្ថយពិន្ទុនៃចំណុចឥរិយាបថក្នុងការសម្របខ្លួនរបស់គាត់/នាង ដែលគួរតែត្រូវបានវាយតម្លៃដោយផ្អែកលើមូលដ្ឋាននៃសមត្ថភាពច្រើនជាងការសហការ នោះទេ។

ការពិចារណាផ្សេងទៀត

ពិការភាពផ្លូវកាយ
ប្រសិនបើពិការភាពផ្លូវកាយរបស់អ្នកដាក់ពាក្យស្នើសុំណាម្នាក់រារាំងនាងពីការធ្វើកិច្ចការណាមួយដោយគ្មានជំនួយនោះ ទោះបីជាវាស្ថិតនៅក្នុងសមត្ថភាពផ្នែកខួរក្បាលរបស់នាងក៏ដោយ កិច្ចការនោះត្រូវតែបានវាយតម្លៃថាជា "មិនធ្លាប់ ឬកម្រ" (ឬអាចស្ថិតនៅក្នុងកម្រិតមធ្យម)។ អ្នកដាក់ពាក្យស្នើសុំមិនគួរទទួលបានការដាក់ទោស ឬរង្វាន់ ដោយសារតែពិការភាពរបស់ខ្លួននោះទេ។ ឧទាហរណ៍ ៖ មនុស្សម្នាក់ដែលប្រើប្រាស់កៅអីរុញអាច ឬមិនអាចទទួលបានការជួយជ្រោមជ្រែងសម្រាប់ចំណុចមួយ ដូចជា *ការលើក និងយួរគ្រឿងទេសមួយថង់ពេញ* អាស្រ័យលើថាតើគាត់អាចធ្វើកិច្ចការនោះដោយឯករាជ្យបានដែរឬទេ។

ការប្រើប្រាស់ឧបករណ៍សម្រាប់ការសម្របខ្លួន
ប្រសិនបើអ្នកដាក់ពាក្យស្នើសុំអាចប្រើប្រាស់បរិក្ខារសម្រាប់ការសម្របខ្លួនរបស់នាងបានដោយឯករាជ្យ ពោលគឺ នាងប្រើប្រាស់ឧបករណ៍សម្រាប់ការសម្របខ្លួនដោយគ្មានជំនួយ ចូរដាក់ពិន្ទុចំណុចនោះ ដូចជាវាត្រូវបានធ្វើយ៉ាងជាក់ស្តែងដែរ។ ប្រសិនបើនាងពាក់វ៉ែនតា តើនាងមើលឃើញបានល្អប៉ុណ្ណាដោយប្រើប្រាស់វ៉ែនតារបស់នាង? តើនាងអាចដើរបានល្អប៉ុណ្ណាដោយប្រើប្រាស់ឈើច្រត់របស់នាង? តើនាងប្រើប្រាស់ស្លាបព្រាបានល្អប៉ុណ្ណា ទោះបីជាវាគឺជាស្លាបព្រាដែលត្រូវបានកែសម្រួលក៏ដោយ?

ឱសថ
ចាត់ទុកឱសថដូចជាបរិក្ខារសម្រាប់ការសម្របខ្លួនដែរ ដូចជា វ៉ែនតា ឬឧបករណ៍ជំនួយដល់ការស្តាប់ ជាដើម។ តើអ្នកដាក់ពាក្យស្នើសុំធ្វើកិច្ចការដោយមានជំនួយពីឱសថរបស់នាងបានល្អប៉ុណ្ណា?

វិធីសាស្ត្រប្រាស្រ័យទាក់ទងជំនួស
ការប្រើប្រាស់ភាសាសញ្ញាផ្លូវការ (ប៉ុន្តែមិនមែនជាការធ្វើកាយវិការសាមញ្ញៗនោះទេ) ត្រូវបានចាត់ទុកថាស្មើនឹងការនិយាយ។ សៀវភៅ ក្តារ និងឧបករណ៍សម្រាប់ការប្រាស្រ័យទាក់ទងអាចត្រូវបានចាត់ទុកថាស្មើនឹងការនិយាយនៅក្នុងលក្ខខណ្ឌដែលឧបករណ៍ទាំងនោះមានពាក្យជាច្រើនដែលអាចរួមបញ្ចូលគ្នាដើម្បីបង្កើតជាឃ្លាពិសេសនានា។ ឧទាហរណ៍ ៖ ការចង្អុលទៅកាន់ពាក្យ ឬសញ្ញា "កន្លែងណា" និងពាក្យ ឬ សញ្ញា "អាវក្រៅ" បង្កើតជាសំណួរសាមញ្ញមួយ។ ការគ្រាន់តែចង្អុលទៅកាន់សញ្ញាអាវធំ ឬសញ្ញាសួរ មិនបង្កើតជាសំណួរសាមញ្ញមួយនោះទេ។

ត្រូវបានសួរ
ចំណុចនានារបស់ ICAP មួយចំនួនតូច ជាញឹកញាប់ គឺជាចំណុចដែលងាយស្រួល ដែលនៅក្បែរចំណុចចាប់ផ្តើមនៃវិស័យណាមួយ តាមធម្មតាត្រូវបានអនុវត្តតែនៅក្នុងការឆ្លើយតបទៅនឹងសំណួរណាមួយតែប៉ុណ្ណោះ (ឧ. *បញ្ជាក់អំពីថ្ងៃខែឆ្នាំកំណើត*)។ នៅក្នុងករណីនេះ ឥរិយាបថនោះអាចត្រូវបានវាយតម្លៃថា *ធ្វើបានល្អណាស់* ទោះបីមនុស្សម្នាក់នោះកំពុងតែឆ្លើយតបនឹងសំណួរណាមួយក៏ដោយ។

កិច្ចការងាយស្រួលពេក
មនុស្សម្នាក់អាចឈប់ធ្វើកិច្ចការណាមួយបន្តទៀតដោយសារតែវាងាយស្រួលពេកសម្រាប់គាត់/នាង។ ចំណុចនានាដែលងាយស្រួលពេកសម្រាប់មនុស្សម្នាក់គួរតែតែងតែត្រូវបានដាក់ពិន្ទុថា *ធ្វើបានល្អណាស់ (3)*។ ឧទាហរណ៍ ៖ ប្រសិនបើមនុស្សម្នាក់ធ្វើបានល្អណាស់ចំពោះកិច្ចការនៃការស្លៀកពាក់ដោយខ្លួនឯងបានយ៉ាងពេញលេញ និងយ៉ាងមានរបៀបរៀបរយ នៅពេលនោះ ការលាដៃ និងជើងនៅខណៈពេលកំពុងស្លៀកពាក់នឹងអាចងាយស្រួលពេកសម្រាប់មនុស្សម្នាក់នោះ និងគួរតែត្រូវបានដាក់ពិន្ទុ a 3។

កិច្ចការដែលមានលើសពីមួយផ្នែក
ប្រសិនបើផ្នែកណាមួយនៃកិច្ចការដែលមានច្រើនផ្នែកត្រូវបានបំពេញបានយ៉ាងល្អ ប៉ុន្តែធ្វើផ្នែកណាមួយផ្សេងទៀតបានល្អបង្គួរតែប៉ុណ្ណោះ ចំណុចនោះត្រូវតែបានដាក់ពិន្ទុ *ល្អបង្គួរ*។ ប្រសិនបើមានផ្នែកណាមួយនៃកិច្ចការមួយដែលមនុស្សម្នាក់មិនអាចធ្វើបានទាល់តែសោះនោះ កិច្ចការ នោះត្រូវតែបានវាយតម្លៃថា *មិនធ្លាប់ ឬកម្រ*។

គ្មានឱកាស
ប្រសិនបើអ្នកដាក់ពាក្យស្នើសុំពុំមានឱកាសនៅក្នុងការធ្វើកិច្ចការណាមួយ ឬមិនត្រូវបានអនុញ្ញាតឲព្យាយាមធ្វើកិច្ចការណាមួយដោយសារតែកត្តានានាក្រៅពីកម្រិតជំនាញរបស់គាត់/នាងនោះ ឧទាហរណ៍ ៖ ប្រសិនបើសកម្មភាពណាមួយ គឺផ្ទុយនឹងវិន័យគ្រួសារ ឬសកម្មភាពណាមួយគឺជា "ការងាររបស់អ្នកណាម្នាក់ផ្សេងទៀត" ប៉ាន់ស្មានថាតើនាពេលបច្ចុប្បន្ន មនុស្សម្នាក់នោះនឹងបញ្ចប់កិច្ចការនោះបានយ៉ាងពេញលេញដែរឬទេ និងបានល្អប៉ុណ្ណា ប្រសិនបើមានឱកាស។

ការប្រាប់ ឬការបង្ហាញ
អាចមានចំណុចណាមួយរបស់ ICAP ដែលអ្នកដាក់ពាក្យស្នើសុំមិនធ្លាប់ត្រូវបានស្នើសុំឲធ្វើនោះទេ។ ការបង្ហាញរបៀបធ្វើកិច្ចការណាមួយទៅកាន់មនុស្សម្នាក់ក្នុងគោលបំណងធ្វើការពន្យល់អំពីអ្វីដែលអ្នកចង់ឲគាត់/នាងធ្វើ មិនត្រូវបានចាត់ទុកថាជាការបណ្តុះបណ្តាល ឬការត្រួតពិនិត្យនោះទេ។

សុវត្ថិភាព

ប្រសិនបើអ្នកដាក់ពាក្យស្នើសុំមិនត្រូវបានអនុញ្ញាតឲធ្វើកិច្ចការណាមួយដោយសារកម្រិតនៃការអនុវត្តរបស់គាត់/នាង និង/ឬការវិនិច្ឆ័យអាចនឹងបណ្តាលឲមានការគម្រាមកំហែងចំពោះសុវត្ថិភាពរបស់គាត់នោះ ចំណុចនោះគួរតែត្រូវបានដាក់ពិន្ទុ *មិនធ្លាប់ ឬកម្រ* (ឬអាចស្ថិតនៅកម្រិត មធ្យម)។ ឧទាហរណ៍ ៖ គ្រាន់តែក្មេងម្នាក់អាចឈោងដល់ និងមួលប្រដាប់សម្រាប់មួលហ្គាសនៅលើចង្ក្រានបាន ពុំមានន័យថាគាត់អាចធ្វើប្រតិបត្តិការចង្ក្រានដោយឯករាជ្យបាននោះទេ។

ការត្រួតពិនិត្យ

ការត្រួតពិនិត្យដែលអ្នកដាក់ពាក្យស្នើសុំទទួលបានអាចច្រើនជាង ឬតិចជាងអ្វីដែលនាងត្រូវការ អាស្រ័យលើចំនួននៃការត្រួតពិនិត្យទូទៅដែល មាននៅក្នុងផ្ទះ ឬទីកន្លែងណាមួយ។ ទោះបីជាយ៉ាងណាក៏ដោយ សិរិយាបថរបស់អ្នកដាក់ពាក្យស្នើសុំគួរតែត្រូវបានវាយតម្លៃដោយពឹងផ្អែកលើសមត្ថភាពរបស់នាងផ្ទាល់នៅក្នុងការធ្វើកិច្ចការដោយឯករាជ្យ មិនមែនផ្អែកលើកម្រិតនៃការត្រួតពិនិត្យទូទៅ ឬរិន័យទូទៅរបស់ទីកន្លែងណាមួយដែលត្រូវបានលើកឡើងនោះទេ។

ស្នើសុំការអនុញ្ញាត

អ្នកដាក់ពាក្យស្នើសុំណាម្នាក់មិនទទួលបានការដាក់ទោសដោយសារការស្នើសុំការអនុញ្ញាតមុនពេលចាប់ផ្តើមធ្វើកិច្ចការណាមួយយ៉ាងសមស្របនោះទេ។ ទោះបីជាមនុស្សម្នាក់នោះមិនបានចាប់ផ្តើមធ្វើកិច្ចការនោះដោយខ្លួនឯងទាំងស្រុងក៏ដោយ ក៏គាត់កំពុងតែចាប់ផ្តើមធ្វើកិច្ចការនោះដោយមានការស្នើសុំការអនុញ្ញាតយ៉ាងសមស្របដែរ។

ការដឹង ការជម្រុញទឹកចិត្ត និងការរំពឹងទុករបស់សង្គម

ដើម្បីទទួលបានពិន្ទុ *ធ្វើបានល្អណាស់* អ្នកដាក់ពាក្យស្នើសុំត្រូវការសមត្ថភាពក្នុងការធ្វើកិច្ចការណាមួយ ការដឹងអំពីពេលវេលាដែលចាំបាច់ត្រូវតែធ្វើកិច្ចការនោះ និងការជម្រុញទឹកចិត្តនៅក្នុងការធ្វើកិច្ចការនោះ ដោយពិចារណាអំពីការរំពឹងទុករបស់សង្គមដែលនៅជុំវិញខ្លួនគាត់។ ចំណុចមួយ ដូចជាសម្អាតបន្ទប់គេងបង្កើតជាឧទាហរណ៍ល្អមួយនៅទីនេះ។

ក្មេងតូច ឬមនុស្សពេញវ័យដែលពិការធ្ងន់ធ្ងរ ដែលខ្វះខាតសមត្ថភាពនៅក្នុងការរៀបចំគ្រែគេងនឹងត្រូវបានដាក់ពិន្ទុ *មិនធ្លាប់ ឬកម្រ* ដោយមិនគិតអំពីការដឹង ឬការជម្រុញទឹកចិត្តនោះទេ។

អ្នកណាម្នាក់ដែលមានសមត្ថភាពធ្វើការសម្អាតបានយ៉ាងល្អ ប្រហែលជាបន្ទាប់ពីមានការបណ្តុះបណ្តាលបន្ថែមមួយជំហានម្តងៗ ប៉ុន្តែមិនអាចអនុវត្តតាមកាលវិភាគបានដោយឯករាជ្យ និងដែលមិនដឹងអំពីពេលវេលា ឬមិនដឹងថាតើជំនាញនោះមានភាពចាំបាច់ដែរឬទេនោះ (ពួកគេតែងតែត្រូវតែបានគេស្នើសុំ) ត្រូវតែបានដាក់ពិន្ទុតិចជាង *ធ្វើបានល្អដោយគ្មានការស្នើសុំ*។

មនុស្សពេញវ័យដែលឯករាជ្យម្នាក់ ដែលតែងតែថែរក្សាផ្ទះមិនឲមានស្នាមអ្វីទាំងអស់ នឹងត្រូវបានវាយតម្លៃថា *ធ្វើបានល្អដោយគ្មានការស្នើសុំ*។

មនុស្សពេញវ័យដែលឯករាជ្យម្នាក់ ដែលតែងតែទុកឲបន្ទប់គេងមានភាពរញ៉េរញ៉ៃ សូម្បីតែនៅពេលដែលមិត្តជិតស្និទ្ធមកលេងក៏ដោយ ប៉ុន្តែត្រូវបានបោសសម្អាតនៅមុនពេលដែលវាប្រែជាគ្មានអនាម័យ និងមុនពេលទទួលយកសេវាពីក្រុមហ៊ុនពិសេស នៅតែអាចត្រូវបានវាយតម្លៃថា *ធ្វើបានល្អ*។ ប្រសិនបើភាពញឹកញាប់នៃការបោសសម្អាតស្ថិតនៅក្នុងដែនកំណត់នៃការរំពឹងទុករបស់សង្គមធម្មតាចំពោះមនុស្សពេញវ័យដែលមិនពិការដែលស្ថិតនៅក្នុងស្ថានភាពនៃការរស់នៅប្រហាក់ប្រហែលគ្នា។

សមាជិកគ្រួសារណាម្នាក់ដែលមានសមត្ថភាពនៅក្នុងការបោសសម្អាតបន្ទប់បានយ៉ាងល្អ ដែលតែងតែធ្វើឲវា យ៉ាងហោចណាស់ក៏មានភាពស្អាតល្អដែរនោះ ប៉ុន្តែជាអ្នកដែលសម្អាតវាបានយ៉ាងស្អាតជាញឹកញាប់តាមដែលវិន័យគ្រួសារតម្រូវ ស្របតាមកាលវិភាគ ឬ "នៅពេលដែលក្រុមហ៊ុនមកដល់" តែប៉ុណ្ណោះ នៅតែត្រូវបានវាយតម្លៃថា *ធ្វើបានល្អ* ប្រសិនបើគាត់តែងតែអនុវត្តតាមសេចក្តីរំពឹងទុករបស់គ្រួសារដោយគ្មានអ្វីច្រើនជាងការផ្តល់យោបល់ ឬការរំឭកម្តងម្កាលនោះទេ។

មនុស្សម្នាក់ដែលមានសមត្ថភាពបោសសម្អាតបានយ៉ាងស្អាត ប៉ុន្តែមិនអនុវត្តតាមកាលវិភាគណាមួយដោយឯករាជ្យ និង តាមធម្មតាខកខានមិនបានប្រើប្រាស់ជំនាញនោះទេ សូម្បីតែនៅពេលដែលសេចក្តីរំពឹងទុករបស់សង្គមតម្រូវយ៉ាងច្បាស់លាស់ក៏ដោយ ដោយសារកង្វះខាតនៃការយល់ដឹង ឬកង្វះខាតនៃការជម្រុញទឹកចិត្ត ប្រហែលជាពាក់ព័ន្ធនឹងបញ្ហាសុខភាពខួរក្បាល ត្រូវតែបានដាក់ពិន្ទុតិចជាង *ធ្វើបានល្អដោយគ្មានការស្នើសុំ*។

សំណួរ

តើអ្នកណាអាចបំពេញ **ICAP** បាន**?**

មាតា/បិតា គ្រូបង្រៀន ឬអ្នកមើលថែទាំណាម្នាក់ដែលស្គាល់អ្នកដែលកំពុងតែត្រូវបានគេវាយតម្លៃយ៉ាងច្បាស់ អាចផ្តល់ព័ត៌មានដែលចាំបាច់ត្រូវបំពេញ ICAP បាន។ នៅក្នុងនាមជាគោលការណ៍ណែនាំមួយ អ្នកនិពន្ធសំណូមពរថា ប្រសិនបើអ្នកឆ្លើយតបមានអន្តរកម្មជាមួយមនុស្ស ម្នាក់នោះជារៀងរាល់ថ្ងៃក្នុងរយៈពេលយ៉ាងតិចបីខែនោះ គាត់/នាងគួរតែស្គាល់អ្នកដាក់ពាក្យស្នើសុំបានច្បាស់គ្រប់គ្រាន់សម្រាប់ការបំពេញ ចំណុចនានានៃឥរិយាបថក្នុងការសម្របខ្លួនរបស់ ICAP ដោយផ្អែកតាមការដឹងដោយផ្ទាល់ខ្លួនរបស់គាត់/នាងអំពីមនុស្សម្នាក់នោះ។ អ្នកឆ្លើយតបអាចបំពេញកូនសៀវភៅ ICAP ដោយផ្ទាល់ (ប្រសិនបើដឹងច្បាស់អំពីគោលការណ៍ណែនាំទាំងនេះ និងសេចក្តីណែនាំកម្រិតមូលដ្ឋានសម្រាប់ការបំពេញ ICAP រួចរាល់ហើយ ដោយយោងដល់ឧបសម្ព័ន្ធ D នៃសៀវភៅណែនាំអំពី ICAP) ឬអាចផ្តល់ព័ត៌មានទៅកាន់អ្នកធ្វើបទសម្ភាសន៍ណាម្នាក់ ដូចជា បុគ្គលិកសង្គម ជាដើម។ វាមិនសំខាន់នោះទេ ថាតើទទួលបានព័ត៌មាននោះដោយរបៀបណា និងពីអ្នកណា ដរាបណាព័ត៌មានអំពីបុគ្គលនោះ និងឥរិយាបថរបស់គាត់កើតឡើងនាពេលបច្ចុប្បន្ន និងត្រឹមត្រូវ។ ប្រហែលជាត្រូវប្រឹក្សាយោបល់ជាមួយអ្នកឆ្លើយតបជាច្រើននាក់។

ចុះប្រសិនបើខ្ញុំដឹងថា អ្នកឆ្លើយតបណាម្នាក់កំពុងតែផ្តល់ការការពារខ្លាំងពេក ឬបោកបញ្ឆោត ឬមានអ្នកឆ្លើយតបពីរនាក់មិនយល់ស្របនោះ?

មាតាបិតាដែលផ្តល់ការការពារខ្លាំងពេកអាចនិយាយថា “គាត់អាចធ្វើកិច្ចការនោះបាន ប៉ុន្តែខ្ញុំមិនឲគាត់ធ្វើ....” នៅក្នុងករណីណាមួយបែបនោះ គោលដៅ គឺដើម្បីទទួលបាន និងកត់ត្រាព័ត៌មានដែលកើតឡើងនាពេលបច្ចុប្បន្ន និងត្រឹមត្រូវ។ សួរសំណួរមួយចំនួនបន្ថែមទៀតដើម្បី កំណត់ថាតើអ្នកដាក់ពាក្យស្នើសុំមានភាពស្ទាត់ជំនាញចំពោះជំនាញនោះដែរឬទេ និងតើគាត់ប្រើប្រាស់ជំនាញនោះយ៉ាងជាក់ស្តែងប្រកបដោយសុវត្ថិភាពបានល្អប៉ុណ្ណា ប្រសិនបើមានឱកាស។ ប្រសិនបើចាំបាច់ ប្រឹក្សាយោបល់ជាមួយអ្នកឆ្លើយតបបន្ថែមទៀត (មាតា/បិតា គ្រូបង្រៀន បុគ្គលិក ឬប្រហែលជាអ្នកដាក់ពាក្យស្នើសុំដោយផ្ទាល់) រហូតទាល់តែអ្នកពេញចិត្តថា ព័ត៌មានដែលអ្នកកត់ត្រានោះឆ្លុះបញ្ចាំងអំពីឥរិយាបថ ពិតប្រាកដរបស់អ្នកដាក់ពាក្យស្នើសុំនៅក្នុងស្ថានភាពធម្មតា

ចុះប្រសិនបើមិនបានបំពេញចំណុចណាមួយនោះ?

ការធ្វើតេស្តនេះមិនអាចដាក់ពិន្ទុបាននោះទេ ប្រសិនបើមិនបានបំពេញចំណុចណាមួយនោះ។ គូសយកចម្លើយមួយសម្រាប់ចំណុចនៃ ឥរិយាបថក្នុងការសម្របខ្លួនទីមួយៗ នៅក្នុងវិស័យទីមួយៗក្នុងចំណោមវិស័យទាំងបួន (77 ចំណុច)។

ចុះប្រសិនបើខ្ញុំមិនដឹងអំពីការអនុវត្តរបស់ម្នាក់ចំពោះចំណុចជាក់លាក់ណាមួយនោះ?

ប្រសិនបើអ្នកពុំមានឱកាសធ្វើការអង្កេតមើលអ្នកដាក់ពាក្យស្នើសុំធ្វើកិច្ចការនោះ ឬប្រសិនបើ អ្នកដាក់ពាក្យស្នើសុំពុំមានឱកាស ឬពុំមាន កាតព្វកិច្ចនៅក្នុងការធ្វើកិច្ចការនោះ ចូរសួរអ្នកណាម្នាក់ផ្សេងទៀតដែលបានអង្កេតមើល ឬធ្វើការប៉ាន់ស្មានថាតើអ្នកដាក់ពាក្យស្នើសុំអាចធ្វើ កិច្ចការនោះនៅពេលនេះដោយគ្មានជំនួយ ឬគ្មានការបណ្តុះបណ្តាលបន្ថែម បានដែរឬទេ និងបានល្អប៉ុណ្ណា។ ចូរផ្អែកការប៉ាន់ស្មានរបស់អ្នកលើព័ត៌មាន ឬការអង្កេតមើលទង្វើរបស់មនុស្សម្នាក់នោះចំពោះកិច្ចការប្រហាក់ប្រហែលគ្នា ឬកិច្ចការដែលពាក់ព័ន្ធ។

ចុះចំពោះជំងឺ ឬការរងរបួសជាបណ្តោះអាសន្ន ដែលមានផលប៉ះពាល់ចំពោះឥរិយាបថវិញនោះ?

ជាទូទៅ ចូរវាយតម្លៃអំពីទង្វើជាមធ្យមរបស់អ្នកដាក់ពាក្យស្នើសុំនៅក្នុងអំឡុងពេលនៃខែថ្មីបំផុត។ ដើម្បីអាចពឹងផ្អែកបាន ការធ្វើតេស្តមួយត្រូវតែ វាស់វែងអំពីឥរិយាបថដែលអាចប្រែប្រួលបាននៅពេលជាក់លាក់ណាមួយ។ ប្រសិនបើអាចធ្វើបាន ពន្យារពេលនៃការវាយតម្លៃរហូតដល់មនុស្ស ដែលមានជំងឺស្រួចស្រាល់ណាម្នាក់មានស្ថានភាពនឹងនរឡើងវិញ។

ចុះចំពោះមនុស្សដែលមានជំងឺខួរក្បាល ដែលទង្វើរបស់គាត់អាចមានភាពប្រែប្រួលនៅក្នុងវដ្តនានាម្តងម្កាលវិញ?

ជាទូទៅ ចូរវាយតម្លៃអំពីទង្វើជាមធ្យមរបស់អ្នកដាក់ពាក្យស្នើសុំនៅក្នុងអំឡុងពេលនៃខែថ្មីបំផុត។ ដើម្បីអាចពឹងផ្អែកបាន ការធ្វើតេស្តមួយត្រូវតែ វាស់វែងអំពីឥរិយាបថដែលអាចប្រែប្រួលបាននៅពេលជាក់លាក់ណាមួយ។ ប្រសិនបើអាចធ្វើបាន ពន្យារពេលនៃការវាយតម្លៃរហូតដល់ អ្នកដាក់ពាក្យស្នើសុំដែលមានជំងឺស្រួចស្រាល់មានស្ថានភាពនឹងនរឡើងវិញ។

ប្រសិនបើខែមុន គឺជាខែដែលមានការប្រែប្រួលនៃឥរិយាបថនៅក្នុងរយៈពេលមួយឆ្នាំ ដែលអាចជាករណីសម្រាប់បញ្ហាសុខភាពខួរក្បាលមួយចំនួនដែលបច្ចុប្បន្នមានភាពល្អប្រសើរឡើងវិញ (ឬអត់) នោះ ភាពខ្លាំងក្លារបស់អ្នកត្រួតពិនិត្យអាចចាំបាច់ត្រូវតែមានភាពប្រែប្រួលនៅក្នុងរយៈពេលពេញមួយឆ្នាំដើម្បីមានភាពស្របគ្នានឹងឥរិយាបថនោះ។ *នេះគឺជាសំណួរអំពីគោលនយោបាយ មិនមែនជាសំណួរនៃការវាយតម្លៃនោះទេ។* គោលនយោបាយដោយមានភាពជាក់លាក់តាមរដ្ឋ ឬទីភ្នាក់ងារនីមួយៗនោះ អាចរួមបញ្ចូលជាសក្តានុពលនូវទាំង ICAP នៃ "ករណីដែលអាក្រក់បំផុត" និង "ករណីដែលល្អបំផុត" រួមជាមួយនីតិវិធីសម្រាប់ដោះស្រាយជាមួយការគ្រប់គ្រងសំណុំរឿងពេញមួយឆ្នាំ។

ចុះចំពោះអ្នកដែលមានភាពទាក់ទាញចំពោះកុមារ ឬជនដែលបង្កអគ្គិភ័យ ឬអ្នកណាម្នាក់ផ្សេងទៀតដែលឥរិយាបថក្នុងការសម្របខ្លួនរបស់គាត់មានកម្រិតខ្ពស់ ប៉ុន្តែភាពឯករាជ្យរបស់គាត់ត្រូវបានដាក់កំហិតដោយតម្រូវការនៃការត្រួតពិនិត្យមិនឈប់ឈរវិញនោះ?

ឥរិយាបថក្នុងការសម្របខ្លួនរបស់អ្នកដាក់ពាក្យស្នើសុំគួរតែត្រូវបានវាយតម្លៃដែលផ្អែកលើសមត្ថភាពរបស់គាត់នៅក្នុងការធ្វើកិច្ចការនានាដោយឯករាជ្យ មិនមែនផ្អែកលើកម្រិតនៃការត្រួតពិនិត្យដែលត្រូវការជាចាំបាច់ដោយសារបញ្ហានៃឥរិយាបថរបស់គាត់នោះទេ។ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំម្នាក់នោះធ្វើ (ឬអាចធ្វើ) កិច្ចការណាមួយ ដូចជា *ការធ្វើសកម្មភាពបានយ៉ាងសមស្របនៅទីសាធារណៈជាមួយមិត្តភ័ក្តិ*នោះ គាត់គួរតែទទួលបានកិត្តិយសសម្រាប់ចំណុចនោះ ទោះបីជាការចេញទៅខាងក្រៅជាមួយមិត្តភ័ក្តិតែម្នាក់ឯង គឺជាប្រឆាំងនឹងវិន័យក៏ដោយ។
អ្នកដាក់ពាក្យស្នើសុំទាំងនោះត្រូវការការត្រួតពិនិត្យច្រើនជាងការដែលឥរិយាបថក្នុងការសម្របខ្លួនរបស់ពួកគេតម្រូវឲធ្វើតាមម៉្យាង។ រដ្ឋមួយចំនួនប្រើប្រាស់សំណួរបំពេញបន្ថែមមួយ បន្ថែមពីលើពិន្ទុរបស់ ICAP ដើម្បីកំណត់កម្រិតនៃការត្រួតពិនិត្យសម្រាប់ស្ថានភាពពិសេសៗទាំងនេះ។ ជាថ្មីម្តងទៀត *នេះគឺជាសំណួរអំពីគោលនយោបាយ មិនមែនជាសំណួរនៃការវាយតម្លៃនោះទេ។*